## តើមានកម្មវិធីអ្វីផ្សេងទៀតដែល DAMEC ផ្តល់ជូន?

ការប្រឹក្សាយោបល់សម្រាប់គ្រួសារ និងគូស្រករ

កម្មវិធីអប់រំ និងព្យាបាលជាក្រុម

ការបកប្រែ

កម្មវិធីសម្រាប់ជនជាតិវៀតណាមបុរស និងស្ត្រី ដែលចាកចេញពីពន្ធនាគារ

***មិនគិតថ្លៃសេវា   និងលាក់ការសំងាត់***

### សម្រាប់ពត៌មានលំអិត និងការបញ្ជូនអតិថិជន

សូមទាក់ទង

ទូរសព្ទ: (02) 8706 0150

ទូរសារ: (02) 8706 0154

អាសយដ្ឋាន: Suite 5, Level 4, 13-14 Moore Street, Liverpool NSW 2170




D.A.M.E.C

Drug and Alcohol Multicultural Education Centre

www.damec.org.au

*មជ្ឈមណ្ឌលអប់រំពហុវប្បធម៌អំពីគ្រឿងញៀន និង គ្រឿងស្រវឹង (DAMEC) គឺជាអង្គការមិនមែនរដ្ឋាភិបាល មានគោលបំណងចំបងក្នុងការកាត់បន្ថយផលប៉ះពាល់ពីការហូបគ្រឿងស្រវឹង និងការប្រើគ្រឿងញៀនដ៏ទៃទៀតនៅក្នុងក្រុមជនជាតិដែលមានដើមកំណើតវប្បធម៌ និងភាសាផ្សេងគ្នា (CALD) ក្នុងរដ្ឋញូវសោធវែល។*



NSW GOVERNMENT | Health

## មជ្ឈមណ្ឌលអប់រំពហុវប្បធម៌អំពី គ្រឿងញៀន និងគ្រឿងស្រវឹង

## D.A.M.E.C.

# សេវាប្រឹក្សាយោបល់សម្រាប់គ្រឿងញៀន និងគ្រឿងស្រវឹង




**ទូរសព្ទ: (02) 8706 0150**

## តើយើងខ្ញុំជានរណា?

យើងខ្ញុំមានសមត្ថភាពដែលត្រូវបានទទួលស្គាល់ មានអ្នកជំនាញប្រឹក្សាយោបល់ មានអ្នកជំនាញព្យាបាល និងប្រឹក្សាជំងឺផ្លូវចិត្ត

## តើអ្វីទៅជាការប្រឹក្សាយោបល់

ការប្រឹក្សាយោបល់ គឺជាការរួមសហការគ្នា ជាដំណើរការ ដែលមានគោលបំណងច្បាស់លាស់រវាងអ្នកផ្ដល់យោបល់ និងអតិថិជន។ វាផ្ដល់ជូនលោកអ្នកនូវឱកាសមួយដើម្បី បង្ហាញនូវអារម្មណ៍ និងការគិតរបស់អ្នកដោយមិនវិនិច្ឆ័យ រកខុសត្រូវ ដោយការគោរព និងយកចិត្តទុកដាក់។

អ្នកប្រឹក្សាយោបល់ផ្ដល់ជូនការជ្រោមជ្រែង ផ្ដល់ជូនពត៌មាន និងបង្ហាញគន្លឹះថ្មីៗដើម្បីការពិនិត្យមើលបញ្ហាជាមួយអ្នក។ គេអាចជួយលោកអ្នកដើម្បីបញ្ជាក់ ដើម្បីឱ្យយល់ និងរក ដំណោះស្រាយលើបញ្ហារបស់លោកអ្នក។

## យើងខ្ញុំផ្ដល់ការប្រឹក្សាយោបល់ពីរភាសា (Bilingual Counselling)

យើងខ្ញុំមានអ្នប្រឹក្សាយោបល់ដែលអាចនិយាយភាសា :

- វៀតណាម
- ខ្មែរ
- ចិនកាតាំង
- ចិនម៉ង់ដារិន
- ចិនតាជីវ
- អារ៉ាប់
- អង់គ្លេស

យើងខ្ញុំអាចផ្ដល់នូវសេវាបកប្រែឯកសារ និងអ្នកបកប្រែ សម្រាប់អ្នកដែលមកពីសហគមន៍ដែលមានភាសាផ្សេងៗ។

## តើកិច្ចបំរើអ្វីខ្លះដែលយើងខ្ញុំមាន ដើម្បីផ្ដល់ជូន?

- ធ្វើការវាយតម្លៃលើគ្រឿងញៀន គ្រឿងស្រវឹង និងផ្លូវចិត្ត។
- ធ្វើអន្តរាគមន៍ដោយការព្យាបាល
- ធ្វើការបញ្ជូនបន្តទៅកិច្ចបំរើផ្សេងៗទៀត
- ចុះទៅមើលតាមផ្ទះប្រសិនបើមានការចាំបាច់

## តើកិច្ចបំរើនេះសម្រាប់អ្នកណា?

- អ្នកទាំងឡាយណាដែលមានបញ្ហាបណ្ដាលមក ពីការប្រើប្រាស់សារធាតុញៀន (អតីត និងបច្ចុប្បន្ន)
- ប្ដីប្រពន្ធ /ដៃគូ
- គ្រួសារ ឬឪពុកម្ដាយរបស់អ្នកមានបញ្ហាមិនឯករាជ (អ្នកដែលធ្វើអ្វីមួយត្រូវការពឹងលើគេ)
- សាច់ញាតិ អ្នកមើលថែ មិត្តភក្តិ
- បងប្អូនបង្កើត